# ប្រភពពាក្យ «វរ្ម័ន»

តាមរយៈសៀវភៅសិក្សាកន្លងមក យើងសង្កេតឃើញថាព្រះបរមនាមព្រះមហាក្សត្រខ្មែរសម័យមុនអង្គរនិងអង្គរ តែមានពាក្យ «–វរ្ម័ន» នៅខាងចុង។ ប៉ុន្តែបើពិនិត្យតាមសិលាចារឹកបុរាណវិញ យើងឃើញសំណេរពាក្យនេះជា «–វម៌្ម» តែប៉ុណ្ណោះ។ នៅក្នុងអត្ថបទនេះ យើងនឹងបង្ហាញអំពីប្រភពពាក្យ «វរ្ម័ន» តាមរយៈសិលាចារឹកខ្មែរ។

នៅក្នុងវចនានុក្រមខ្មែរ ពន្យល់ពាក្យ «វរ្ម័ន» មានន័យថា គ្រោះ អាវក្រោះ ដែលមានប្រភពមកពីពាក្យសំស្ក្រឹតថា «វម៌និ»។[១] យើងចាប់ផ្ដើមស្គាល់និងសរសេរពាក្យនេះជា «វរ្ម័ន» តាមរយៈឯកសារបារាំងនិងសរសេរត្រាប់តាមសំណេរ «varman»។ យើងដឹងហើយថា អ្នកដែលចាប់ផ្ដើមស្រាវជ្រាវប្រវត្តិសាស្ត្រខ្មែរដែលមានលក្ខណៈវិទ្យាសាស្ត្រ ដោយពឹងផ្អែកជាសំខាន់លើឯកសារសិលាចារឹកបុរាណខ្មែរ គឺក្រុមអ្នកស្រាវជ្រាវជាតិបារាំង។ កាលដើមឡើយ នៅពេលបកប្រែអត្ថបទឬសរសេរតាមលំនាំអត្ថបទអ្នកស្រាវជ្រាវទាំងនោះ យើងក៏សរសេរត្រាប់តាមសំណេរ «varman» មកជាខ្មែរថា «វរ្ម័ន» ដោយពុំបានមើលអក្ខរាវិរុទ្ធតាមរយៈសិលាចារឹកនោះឡើយ។ លោកស្រីបណ្ឌិត ពៅ សាវរស លើកឡើងថាអ្នកប្រាជ្ញខាងវិជ្ជាឥណ្ឌាជាន់មុន បានសរសេរពាក្យ «varman» មាន «–n» នៅខាងចុង ដោយសារភ្ជាប់រឿងនេះទៅនឹងវប្បធម៌ទមិឡដែលរមែងសរសេរបែបនោះ។

បើមើលតាមភ្នែកខ្មែរ និងពិនិត្យមើលអត្ថបទសិលាចារឹកខ្មែរបុរាណសម័យមុនអង្គរនិងអង្គរ យើងឃើញមានតែសំណេរ «–វម៌្ម»[២] តែម្យ៉ាងប៉ុណ្ណោះ[៣]។ បន្ទាប់មក នៅសម័យក្រោយអង្គរ ពាក្យនេះក្លាយសំណេរមកជា «–ពម៌្ម» ដូចមាននៅក្នុងពង្សាវតារឬឯកសារផ្សេងៗសរសេរជា «–ពាណ៌»។ ដូច្នេះព្រះនាមព្រះបាទស្រីសុរិយោពាណ៌ គឺគួរតែជាពាក្យ «សុរិយោពម៌្ម» ដែលក្លាយមកពីពាក្យសម័យអង្គរថា «សូយ៌្យវម៌្ម»[៤] ដែលជា

---

[១] វចនានុក្រមខ្មែរ

[២] ពេលខ្លះប្រើជា «វម៌» ដែរ ប៉ុន្តែមានចំនួនតិចតួចប៉ុណ្ណោះ។

[៣] សូមអាន៖ POU Saveros, 1967: pp. 123 និង POU Saveros, 2001 pp. 237-239។

[៤] សូមអាន៖ ឈឹម ក្រសេម, ១៩៨៤: ១៣៣-៤។

អត្ថបទដោយ៖ លោក ហ៊ុន ឈុនតេង

ទំនៀមតមកពីសម័យអង្គរ ដូចជាព្រះនាម «ជ័យវម៌្ម» ដែលមានច្រើនអង្គដូច្នេះឯង។ នៅក្នុងសិលាចារឹកខ្មែរ ពុំមានសំណេរ «–វម៌ន៑» ឬ «–វម៌្មន៑» ឡើយ។

យើងដឹងស្ទើរគ្រប់គ្នារួចហើយថា នៅសម័យបុរាណ តាំងពីសម័យមុនអង្គរនិងអង្គរ ខ្មែរទទួលឥទ្ធិពលផ្នែកពាក្យសព្ទយ៉ាងច្រើនពីភាសាសំស្ក្រឹត។ យ៉ាងនេះក្តី ខ្មែរពុំបានយកលក្ខណៈពាក្យសំស្ក្រឹតមកប្រើនោះទេ ពោលគឺខ្មែរប្រើតាមការស្រួលមាត់និងលក្ខណៈភាសាខ្មែរ ដែលយើងនិយមហៅថា «ខេមរនីយកម្ម»។ ពាក្យដើមរបស់សំស្ក្រឹតដែលសរសេរជា «វម៌ន៑» ឬ «វម៌្មន៑» នោះ ខ្មែរពុំប្រើតាមឡើយ គឺប្រើត្រឹមតែ «វម៌្ម» ប៉ុណ្ណោះ ដោយពុំមាន «–ន» នៅខាងចុងឡើយ។ បើយើងមើលឱ្យវែងឆ្ងាយបន្តិចទៅទៀត យើងនឹងឃើញថា ពុំមែនមានតែករណីពាក្យ «វម៌្ម» នេះតែមួយប៉ុណ្ណោះទេ គឺមានពាក្យផ្សេងទៀតដូចខាងក្រោមនេះ៖

| ពាក្យសំស្ក្រឹត | ពាក្យខ្មែរបុរាណ |
|---|---|
| គម៌ន៑ | គម៌្ម(សម៌្ម) (K.134: 22&26, K.154B: 10 etc.) |
| ចក្រវត៌ិន៑ | ចក្រវត្តិ៌ (K.235C: 73) |
| គុណទោឞទឝ៌ិន៑ | គុណទោឞទឝ៌ិ(គុណទោសទស៌ិ) (K. 340: 10 etc.) |
| វ្យវហារិន៑ | វ្យវហារិ/វ្យវហារិ (K.344: 6&9, K.249: 4) |
| ឝ្រេឞ្ឋិន៑ | ឝ្រេឞ្ឋ/ឝ្រេឞ្ឋិ(ស្រេស្ឋ/ស្រេស្ឋិ) (K.259S: 22, K.262: 26&34) |

ដូច្នេះ ម្ចាស់សំណេរអត្ថបទណា ដែលពឹងផ្អែកតែលើឯកសារបរទេស ដោយមិនបានពិនិត្យមើលលើសិលាចារឹកខ្មែរបុរាណ ឬក៏ពុំបានពិនិត្យអំពីលក្ខណៈភាសាខ្មែរ អាចនឹងសរសេរសង់ពាក្យទាំងនោះមកជាខ្មែរវិញដូចជា៖ សម៌ន/សរ្ម័ន(śarman) ចក្រវ៉ាតិន/ចក្រវាតិ៌ន (cakravartin)[៩] គុណទោសិ៌ន(guṇadoṣadarṣin) វ្យវហារិន(vyavahārin) និងស្រេស្ឋិន(śreṣṭhin) ពុំខាន។ លុះតែសរសេរ អាន និងប្រើតាមការគ្រាប់សង់សំណេរបរទេសដូច្នោះយូរៗទៅ ក៏ក្លាយជាទម្លាប់។ តើទម្លាប់បែបនេះ អាចកែបានឬពុំបាន?

[៩] សូមអាន៖ ត្រឹង ង៉ា : ១៩៧៣

អត្ថបទដោយ៖ លោក ហ៊ុន ឈុនតេង

គួរបញ្ជាក់ផងដែរថា នៅសម័យមុនអង្គរ ព្រះបរមនាមព្រះមហាក្សត្រខ្មែរមានពាក្យ «–វ្ម៌» នៅខាងចុង លុះមកដល់សម័យអង្គរ មានពាក្យ «–វ្ម៌ទេវ» នៅខាងចុង។ ចំណែកឯពាក្យ «–វ្ម៌» នៅសម័យអង្គរវិញ ប្រើចំពោះក្រុមញាតិវង្ស មានព្រះអង្គម្ចាស់ជាដើម។

## បញ្ជីរូបភាព



ពាក្យ «វ្ម៌ ពម្ម៌ ពាណ៌» នៅក្នុងសិលាចារឹកនិងឯកសារសំណេរ

អត្ថបទដោយ៖ លោក ហ៊ុន ឈុនតេង



សិលាចារឹកប្រាសាទជ្រៃ K.149 មានចារឹកព្រះនាមព្រះបាទភវវម៌្ម មហេន្ទ្រវម៌្ម និងឥសានវម៌្ម
(ប្រភពរូប៖ EFEO_ CAM16677)



សិលាចារឹក K.713

អត្ថបទដោយ៖ លោក ហ៊ុន ឈុនតេង

AMS



សិលាចារឹកសម័យលង្វែក នៅប្រាសាទអង្គរវត្ត មានចារឹកពាក្យ «ស្រីត្រីភវនាទិត្យពម្ន៌»

អត្ថបទដោយ៖ លោក ហ៊ុន ឈុនតេង

## ឯកសារយោង

ឈឹម ក្រសេម.

១៩៤៨. *សិលាចារឹកនគរវត្ត*, មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ, ប៉ារីស។ វចនានុក្រមខ្មែរ.

១៩៦៨. *វចនានុក្រមខ្មែរ ភាគ២*, ទំព័រ៨៦៩

POU Saveros,

(1967), Recherches sur le vocabulaire cambodgien. (I) Mots khmers considérés à tort comme d'origine savante, *JA*, 1967, 1: 117-131.

(2001), Society, Economics and Politics in Pre-Angkor Cambodia: The 7th-8th Centuries by Michael Vickery in *Journal of the Economic and Social History of the Orient* Vol. 44, No. 2, pp. 237-239